# កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល
# ប្រសិនខ្ញុំជាសម្លេង ...

ថ្នាក់ទី 5 - សិល្បៈភាសាអង់គ្លេស - អានអក្សរសិល្ប៍ 5.4

| ស្តង់ដារមុខវិជ្ជាស្នូល | ជាមូលដ្ឋាន ត្រង់នេះមានន័យថា កូនរបស់អ្នក ... |
|---|---|
| RL.5.4 កំណត់អត្ថន័យនៃពាក្យ និងឃ្លា នៅពេលដែលត្រូវបានប្រើក្នុងអត្ថបទ រួមទាំងការប្រើប្រាស់អត្ថបដិរូប ដូចជាការប្រៀបប្រដូច និងការប្រៀបធៀប។ | យល់ពី ការប្រៀបធៀប និងការប្រៀបប្រដូច។ |

## ព័ត៌មានគោល៖

អ្នកនិពន្ធដ៏ឆ្នើមបំផុតគឺត្រូវបានគេចងចាំដោយសារការប្រើប្រាស់ពាក្យប្រដូចរបស់ពួកគេ។ ឬម្យ៉ាងទៀត ពួកគេបង្កើតរូបភាពដោយប្រើប្រាស់ពាក្យពេចន៍សម្រាប់អ្នកអាន។ ឧទាហរណ៍ ឃ្លា "វាកំពុងភ្លៀងដូចរហែកមេឃ" ពិពណ៌នាបញ្ជាក់អត្ថន័យជាងឃ្លា "វាកំពុងភ្លៀងនៅខាងក្រៅ"។

នៅពេលដែលអ្នកពិពណ៌នាអ្វីមួយដោយការប្រៀបធៀបវាទៅនឹងអ្វីមួយផ្សេងទៀត អ្នកកំពុងប្រើប្រាស់អត្ថបដិរូប។ អត្ថបដិរូបជារឿយៗប្រើប្រាស់វិញ្ញាណទាំងប្រាំ រួមមាន៖ ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ ជីវ្ហាវិញ្ញាណ ឬឃានវិញ្ញាណ។

**ការប្រៀបធៀប** (Simile) គឺនៅពេលដែលវត្ថុពីរត្រូវបានប្រៀបធៀប ពីព្រោះពួកវាមានលក្ខណៈដូចគ្នា។ ពាក្យ **ដូចជា** ឬ **ដូច** គឺត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបពាក្យពីរ។ ឧទាហរណ៍៖ ត្រជាក់ដូចជាច្រមុះឆ្កែ។

**ការប្រៀបប្រដូច** (Metaphor) ក៏ជាការប្រៀបធៀបវត្ថុពីរផងដែរ ប៉ុន្តែវាជាការប្រៀបប្រដូច **ដោយមិន** ប្រើប្រាស់ពាក្យ ដូចជា ឬ ដូច ឡើយ។ ឧទាហរណ៍ ៖ ហាងនោះគឺជាអណ្តូងរ៉ែមាសតូចមួយ។

នៅក្នុងសកម្មភាពនេះ កូនរបស់អ្នកនឹងប្រើប្រាស់អត្ថបដិរូបដើម្បីបំពេញប្រយោគរបស់ពួកគេ។

## សកម្មភាព៖

1. ផ្តល់ហ្វឺត និងក្រដាសមួយសន្លឹកទៅកូនរបស់អ្នក។
2. ឲ្យកូនរបស់អ្នកបំពេញនូវការរៀបរាប់ខ្លីខាងក្រោមដោយសរសេរ៖

   ប្រសិនបើខ្ញុំជាម្ហូបអាហារ អ្នកនឹងទទួលរសជាតិ . . .
   ប្រសិនបើខ្ញុំជាគ្រឿងក្រអូប អ្នកនឹងទទួលក្លិន . . .
   ប្រសិនបើខ្ញុំជាសម្លេង អ្នកនឹងលឺសូរ . . .
   ប្រសិនបើខ្ញុំជាទេសភាព អ្នកនឹងមើលឃើញ . . .
   ប្រសិនបើខ្ញុំជាកាយវិញ្ញាណ អ្នកនឹងមានអារម្មណ៍ . . .

3. តម្រូវឲ្យកូនរបស់អ្នកពន្យល់បកស្រាយអំពី "រូបភាពពាក់កណ្តាលខ្លួន" របស់ពួកគេ ហើយដាក់វានៅលើទូរទឹកកក។ អ្នកក៏អាចតម្រូវឲ្យកូនរបស់អ្នកសរសេរបកស្រាយរូបភាពពាក់កណ្តាលខ្លួនបន្ថែមទៀតរបស់សមាជិកគ្រួសារ

## សម្ភារដែលអ្នកត្រូវការ៖

⑥ ហ្វឹត
⑥ ក្រដាស

## ឧទាហរណ៍៖

- ប្រសិនខ្ញុំជាម្ហូបអាហារ អ្នកនឹងទទួលរសជាតិស៊ីណាម៉ុន និងស្ករ។
- ប្រសិនបើខ្ញុំជាគ្រឿងក្រអូប អ្នកនឹងទទួលក្លិនកាហ្វេក្តៅៗ និងចង់ញ៉ាំ។
- ប្រសិនបើខ្ញុំជាសម្លេង អ្នកនឹងឮសូរតន្ត្រីពីចម្ងាយ និងសម្លេងសើច។
- ប្រសិនបើខ្ញុំជាទេសភាព អ្នកនឹងមើលឃើញមហាសមុទ្រពណ៌បៃតងនៅពេលថ្ងៃក្តៅ។
- ប្រសិនបើខ្ញុំជាកាយវិញ្ញាណ អ្នកនឹងមានអារម្មណ៍នៃការអោប។